ActionAid Cambodia
#33, Street 71,
Sangkat Tonle Bassa
Khan Chamkarmon
Phnom Penh
Cambodia

Phone+855(0)23 211 461/462
Email: e-mail_cambodia@actionaid.org

actionaid

# ឯកសារស្នើសម្រង់តម្លៃ
# ការផ្គត់ផ្គង់ និងដំឡើងផ្ទាំងប៉ាណូ

## សេចក្ដីផ្ដើម

អង្គការអាក់សិនអេតកម្ពុជា បានចាប់ផ្ដើមអនុវត្តគម្រោងថ្មីមួយឈ្មោះថា ការជម្រុញប្រព័ន្ធ ប្រកាសឱ្យដឹងមុននៅកម្ពុជា។ គម្រោងនេះមានគោលបំណងបង្កើតប្រព័ន្ធប្រកាសឱ្យដឹងមុន ដែលអាចដំណើរការ បាននៅក្នុងប្រទេសកម្ពុជា ដោយមានការសម្របសម្រួល និងការគាំទ្រយ៉ាងរឹងមាំពីក្រសួងពាក់ព័ន្ធរបស់រដ្ឋាភិបាល ដើម្បីធានាបាននូវការប្រកាសឱ្យដឹងមុនអំពីហានិភ័យគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាពទៅដល់ប្រជាសហគមន៍ដែលរស់នៅក្នុងតំបន់ដែលងាយរងគ្រោះដោយគ្រោះមហន្តរាយ។

គម្រោងនេះនឹងត្រូវបានអនុវត្តក្នុងរយៈពេល១៨ខែ ចាប់ផ្ដើមពី ខែវិច្ឆិកា ឆ្នាំ២០២៣ ដោយមានការគាំទ្រថវិកាពី GSMA Innovative Fund (GSMAIF) ចក្រកពអង់គ្លេស ក្នុងខេត្តចំនួន ១១ រួមមាន ខេត្តក្រចេះ ស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ ពោធិ៍សាត់ កំពង់ស្ពឺ កំពត កោះកុង កំពង់ធំ ស្វាយរៀង និងខេត្តព្រៃវែង។។

ក្នុងរយៈពេលនៃការអនុវត្តគម្រោង អង្គការអាក់សិនអេតកម្ពុជា នឹងធ្វើការផ្សព្វផ្សាយទៅកាន់សហគមន៍ឱ្យបានយល់ដឹងអំពីការត្រៀមខ្លួនមុនពេលគ្រោះមហន្តរាយ និងជាពិសេសប្រព័ន្ធប្រកាសឱ្យដឹងមុនអំពីគ្រោះមហន្តរាយដូចជា គ្រោះទឹកជំនន់ ឬគ្រោះរាំងស្ងួតជាដើម ដោយមានជាខិត្តបណ្ណចែកជូនទៅកាន់សហគមន៍ ផ្ទាំងព័ត៌មាននៅតាមឃុំគោលដៅ ឬសាលារៀន និងមានគម្រោងដំឡើងផ្ទាំងប៉ាណូអំពីគ្រោះមហន្តរាយតាមសហគមន៍ផងដែរ។

ដើម្បីសម្រេចនូវលទ្ធផលខាងលើ អង្គការអាក់សិនអេតកម្ពុជា បាននឹងកំពុងស្វែងរកសំណើពីក្រុមហ៊ុនអ្នកផ្គត់ផ្គង់ ដែលមានសមត្ថភាពសម្រាប់ផ្គត់ផ្គង់ និងដំឡើងផ្ទាំងប៉ាណូដូចខាងក្រោម៖

## ១. លក្ខណៈបច្ចេកទេស

| ប្រភេទសម្ភារៈ | បរិយាយ | បរិមាណ |
|---|---|---|
| ផ្ទាំងប៉ាណូ | • ព្រីនផ្ទាំងប៉ាណូរូបភាព (Color)<br>• ទំហំផ្ទាំងប៉ាណូ ២ ម៉ x ៣ ម៉<br>• ដំឡើងផុតពីដី កម្ពស់ ២ម៉ែត្រ<br>• គ្រោងជើងទម្រ ដែក<br>• មានលក្ខណៈរឹងមាំ ធន់នឹងកម្លាំងខ្យល់ ឬភ្លៀង | ៤៧ |

## ២. ទីតាំងផ្គត់ផ្គង់សម្ភារៈ

ActionAid Cambodia
#33, Street 71,
Sangkat Tonle Bassa
Khan Chamkarmon
Phnom Penh
Cambodia
Phone+855(0)23 211 461/462
Email: e-mail_cambodia@actionaid.org

| សម្ភារៈត្រូវការ | | ទីតាំងដំឡើងផ្ទាំងប៉ាណូ | ចំនួន |
|---|---|---|---|
| ផ្ទាំងប៉ាណូ និងការតំឡើង | 1 | កំពង់ធំ | ៣ |
| | 2 | ព្រៃវែង | ៣ |
| | 3 | ស្វាយរៀង | ៣ |
| | 4 | កោះកុង | ៣ |
| | 5 | កំពត | ៥ |
| | 6 | ពោធិ៍សាត់ | ៥ |
| | 7 | កំពង់ស្ពឺ | ៥ |
| | 8 | ឧត្តរមានជ័យ | ៥ |
| | 9 | ព្រះវិហារ | ៥ |
| | 10 | ក្រចេះ | ៥ |
| | 11 | ស្ទឹងត្រែង | ៥ |
| | | សរុប | ៤៧ |

សំគាល់៖ សេចក្តីលំអិតអំពីរូបភាពសំភារៈ សូមមើលឯកសារភ្ជាប់។

### ៣. អំពីតម្លៃ

សម្រង់តម្លៃសម្ភារៈទាំងអស់ក្នុងចំនុច ១ ខាងលើ ត្រូវបានកំណត់ និងមានអត្រាតម្លៃជា ដុល្លារអាមេរិក ដោយគិតដាក់បញ្ចូលទាំងថ្លៃពន្ធផ្សេងៗ រួមបញ្ចូលថ្លៃដឹកជញ្ជូនដល់ទីតាំងនិងតំឡើង និងបញ្ជាក់លក្ខខណ្ឌនៃការទូទាត់ ទំនិញឱ្យបានច្បាស់លាស់។

បញ្ជាក់៖ ក្រុមហ៊ុនអ្នកផ្គត់ផ្គង់ដែលចុះបញ្ជីត្រូវបានលើកទឹកចិត្ត ហើយឯកសារសម្រង់តម្លៃ សូមភ្ជាប់មកជាមួយនូវឯកសារចុះបញ្ជី ក្រុមហ៊ុន និងបណ្ណប៉ាតង់ដែលមានសុពលភាពដែលអាចបង្ហាញពីការប្រតិបត្តិការរបស់ក្រុមហ៊ុនពិតប្រាកដ។

### ៤. ការប្រគល់ទំនិញ

ត្រូវបញ្ជាក់អំពីទំនិញដែលមានក្នុងស្តុកដែលអ្នកផ្គត់ផ្គង់អាចមានលទ្ធភាពប្រគល់ទំនិញដល់ទីតាំងនីមួយៗ ចន្លោះពី**ថ្ងៃទី០១ ដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៤**។

ActionAid Cambodia
#33, Street 71,
Sangkat Tonle Bassa
Khan Chamkarmon
Phnom Penh
Cambodia

Phone+855(0)23 211 461/462
Email: e-mail_cambodia@actionaid.org

actionaid

### ៥. ការធានាគុណភាព

ដើម្បីបញ្ជាក់ពីគុណភាពសំភារៈ ក្រុមហ៊ុនឬអ្នកផ្គត់ផ្គង់ ត្រូវបង្ហាញនៅក្នុងសម្រង់តម្លៃឱ្យបានច្បាស់នូវប្រភេទសម្ភារៈ ទំហំ បច្ចេកទេសក្នុងការដំឡើង (ដោយភ្ជាប់នូវរូបភាព) និងការធានាលើគុណភាពសំភារៈឱ្យបានច្បាស់លាស់។

### ៦. អំពីការផ្ញើសម្រង់តម្លៃ

សម្រង់តម្លៃទាំងអស់ត្រូវ ដាក់ក្នុងស្រោមសំបុត្របិទជិត រួចផ្ញើមកកាន់ការិយាល័យអង្គការអាក់សិនអេតកម្ពុជា នៅទីក្រុងភ្នំពេញ ឱ្យបានត្រឹម**ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤** តាមអាសយដ្ឋាន៖ ផ្ទះលេខ ៣៣ ផ្លូវលេខ ៧១ សង្កាត់ទន្លេបាសាក់ ខណ្ឌ ចំការមន ទូរសព្ទទំនាក់ទំនង៖ ០២៣ ២១១ ៤៦១។